# សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង ប្រធានគណបក្សប្រជាជនកម្ពុជា

## ថ្លែងក្នុងកិច្ចប្រជុំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តចិន

## សន្ទនាជាមួយគណបក្សនយោបាយនៅលើពិភពលោក (ពេញអង្គលើកទី១)

## ក្រោមប្រធានបទ : រួមគ្នាកសាងសហគមន៍នៃអនាគតរួម សម្រាប់មនុស្សជាតិ និងពិភពលោកស្រស់ស្អាត

## រដ្ឋធានីប៉េកាំង, សាធារណរដ្ឋប្រជាមានិតចិន, ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧

- *ឯកឧត្តមប្រធានាធិបតី ស៊ី ជីនភីង (Xi Jinping), អគ្គលេខាធិការបក្សកុម្មុយនីស្តចិន;*
- *ឯកឧត្តម, លោកជំទាវ, សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ការិយាល័យនយោបាយបក្សកុម្មុយនីស្តចិន;*
- *ឯកឧត្តម, លោកជំទាវ, តំណាងគណបក្សនយោបាយ;*
- *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !*

ថ្ងៃនេះខ្ញុំមានកិត្តិយស និង ក្តីសោមនស្សក្រៃលែង ដោយបានចូលរួមក្នុង កិច្ចប្រជុំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តចិន សន្ទនាជាមួយគណបក្សនយោបាយនៅលើពិភពលោក ក្រោមប្រធានបទ រួមគ្នាកសាងសហគមន៍នៃអនាគតរួម សម្រាប់មនុស្សជាតិ និង ពិភពលោកស្រស់ស្អាត ។ ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមថ្លែងអំណរគុណដល់បក្ស និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានផ្តល់ការស្វាគមន៍យ៉ាងកក់ក្តៅចំពោះរូបខ្ញុំ និងគណៈប្រតិភូ ។

ប្រធានបទសម្រាប់កិច្ចពិភាក្សាថ្ងៃនេះ ពិតជាមានសារៈសំខាន់ណាស់ ដោយក្នុងរយៈពេលប្រមាណមួយទសវត្សចុងក្រោយនេះ យើងទាំងអស់គ្នាបានឃើញកាន់តែច្បាស់នូវការប្រែប្រួលយ៉ាងខ្លាំង នូវនិម្មាបនកម្មសេដ្ឋកិច្ច, ពាណិជ្ជកម្ម និង ភូមិសាស្ត្រនយោបាយ, ទាំងក្នុងកម្រិតតំបន់ និង សកលលោក, ជាពិសេស គឺការប្រែប្រួលភូមិសាស្ត្រនយោបាយ ពីឯកប៉ូល មកកាន់ពហុប៉ូល និង ការលេចឡើងនៃមហាអំណាចសេដ្ឋកិច្ចថ្មី ជាអាទិ៍ ប្រទេសចិន ។ ជាមួយនឹងការអភិវឌ្ឍឈានទៅមុខជាលំដាប់, ពិភពលោកក៏កំពុងតែប្រឈមនឹងការកើនឡើងនៃវិសមភាពសង្គម, ទាំងនៅក្នុងប្រទេសអភិវឌ្ឍ និង ប្រទេសកំពុងអភិវឌ្ឍ ។ ទន្ទឹមនេះ, យើងក៏បានសង្កេតឃើញនូវការកើនឡើងនៃអំពើហិង្សា, អំពើភេរវកម្ម និង ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងពីសំណាក់មហាអំណាចខ្លះ ដែលបង្កជាជម្លោះផ្ទៃក្នុង និង បរិវត្តពណ៌ នៅក្នុងតំបន់ និង បណ្តាប្រទេសមួយចំនួន ដែលជាហេតុនាំឱ្យប្រទេសរងគ្រោះទាំងនោះ ធ្លាក់ចូលទៅក្នុងភ្នក់ភ្លើងនៃសង្គ្រាមរ៉ាំរ៉ៃ, នាំមកនូវវិនាសកម្ម និង សោកនាដកម្មដ៏ខ្លោចផ្សា, ទាំងក្នុងផ្នែកសេដ្ឋកិច្ច និង សង្គម ។

ខ្ញុំជឿថា យើងទាំងអស់គ្នាពិតជាចង់បាននូវពិភពលោកមួយ ដែលប្រទេស និង ប្រជាជាតិទាំងអស់ អាចរួមរស់ជាមួយគ្នា នៅក្នុងសុខសន្តិភាព ស្ថិរភាព និង ភាពសុខដុមរមនា, គោរពអធិបតេយ្យភាព និង បូរណភាពទឹកដីគ្នាទៅវិញទៅមក ហើយតម្កល់ការលើកកម្ពស់កិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក

និង ការអភិវឌ្ឍ ជាអាទិភាព និង ជាបំណងប្រាថ្នាខ្ពស់បំផុតរបស់ខ្លួន ដូចដែលមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ។ ក្នុងស្មារតីនេះ, កម្ពុជាសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះការដាក់ចេញនូវគោលការណ៍ចម្បងនៃគោលនយោបាយការទូតរបស់ចិន ដោយឯកឧត្តមប្រធានាធិបតី **ស៊ី ជីនភីង** (Xi Jinping) ពោលគឺ គោលការណ៍ **«ផ្តែកលើសហគមន៍សកលលោករួមមួយ ដែលមាននោគវាសនារួមគ្នា ដោយចាត់ទុកសុខុមាលភាពប្រជាជនជាអាទិភាពកំពូល»** ។ ក្នុងន័យនេះ, ខ្ញុំយល់ថា ឯកឧត្តមប្រធានាធិបតី **ស៊ី ជីនភីង** (Xi Jinping) បានពុចច់ តម្លៃ-ស្នូល របស់គណបក្សនយោបាយទាំងអស់ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំជាន់ខ្ពស់នេះ ពីព្រោះ ពិភពលោក បាន និង កំពុងតែផ្សារភ្ជាប់គ្នាយ៉ាងស្អិតរមួត ទាំងក្នុងវិស័យសេដ្ឋកិច្ច និង សង្គម ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រកបដោយចីរភាព និង ភាពរឹងមាំ ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !**

ជាការរួមចំណែកដល់កិច្ចពិភាក្សារបស់យើង ស្តីពីការបង្កើតនូវសហគមន៍នៃអនាគតរួមសម្រាប់មនុស្ស-ជាតិ, ខ្ញុំសូមចូលរួមចែករំលែកនូវទស្សនៈមួយចំនួន ដូចខាងក្រោម ÷

**ទី១. ការគោរពអធិបតេយ្យ និង ជម្រើសផ្លូវដើររបស់ប្រទេសដោយខ្លួនឯង :** យើងត្រូវតែគោរពអធិប-តេយ្យភាព និង ជម្រើសផ្លូវដើររបស់ប្រទេសដោយខ្លួនឯង មិនថាប្រទេសនោះធំ ឬ តូច, ខ្លាំង ឬ ខ្សោយ នោះទេ ។ និយាយម្យ៉ាងទៀត, ប្រទេសទាំងអស់ ត្រូវតែប្រកាន់ខ្ជាប់នូវគោលការណ៍មិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងគ្នា និង ត្រូវគោរពសិទ្ធិរបស់ប្រទេសដទៃ ក្នុងការជ្រើសរើសប្រព័ន្ធគ្រប់គ្រង និង មាគ៌ាអភិវឌ្ឍន៍ ដោយឯករាជ្យ និង គ្មានការរំខាន ។ ច្បាស់ណាស់, អ្វីដែលល្អសម្រាប់ប្រទេសមួយ មិនប្រាកដថាល្អសម្រាប់ប្រទេសផ្សេងទៀតនោះទេ ដោយសារតែលក្ខណៈពិសេសដោយឡែកផ្សេងគ្នារបស់ប្រទេសនីមួយៗ នៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិតសង្គម ។

**ទី២. ការកសាង និង ថែរក្សាសន្តិភាព និង សន្តិសុខ :** សន្តិភាព និង សន្តិសុខ ក្នុងប្រទេស និង តំបន់ គឺជាមូលដ្ឋានគ្រឹះមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍ ។ ដូច្នេះ, ការកសាង និង ថែរក្សាឱ្យខាងតែបាន នូវសន្តិភាព និង សន្តិសុខ គឺជាអាទិភាពខ្ពស់បំផុតរបស់ប្រទេសនីមួយៗ ។ នៅក្នុងបរិការណ៍នៃបទពិសោធន៍របស់កម្ពុជា, ការ-សម្រេចបាននូវសន្តិភាព, ឯកភាពជាតិ និង ស្ថិរភាពនយោបាយពេញលេញ ក្នុងរយៈពេលជាង ២ ទសវត្សរ៍ចុងក្រោយនេះ, តាមរយៈ **គោលនយោបាយ ឈ្នះ-ឈ្នះ** របស់រាជរដ្ឋាភិបាល, បានបង្កើតឡើងនូវភាពអនុវត្តភាពមិនធ្លាប់មានពីមុនមក សម្រាប់ការកែទម្រង់ដ៏ទូលំទូលាយ និង ការទទួលបាននូវទំនុកចិត្តពីសំណាក់សាធារណៈជន ជាពិសេស ពីសំណាក់វិនិយោគិនឯកជន, ទាំងក្នុង និង ក្រៅប្រទេស, ដែលបានផ្តល់ផលជាកំណើនសេដ្ឋកិច្ច ជាមធ្យម ៧,៧% ក្នុងមួយឆ្នាំ និង ភាពប្រសើរឡើងជាលំដាប់នៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទាំងប្រទេស ។

**ទី៣. ការកាត់បន្ថយភាពក្រីក្រ, ការកាត់បន្ថយគម្លាតសង្គម និង ការពង្រឹងសុវត្ថិភាពសង្គម :** ការរក្សានូវសន្តិភាព និង សន្តិសុខ ឱ្យមាននិរន្តរភាព ទាមទារជាចាំបាច់ នូវការដោះស្រាយបញ្ហាសង្គមនានា ដូចជា បញ្ហាវិសមភាព, ការកាត់បន្ថយភាពក្រីក្រ និង ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ដែលបញ្ហាទាំងអស់នេះ គឺជាឫសគល់នៃភាពចលាចល និង បដិវត្តន៍ នៅកន្លែងមួយចំនួននៅលើពិភពលោក ។ ដូច្នេះ, ការដោះស្រាយបញ្ហានៃភាពក្រីក្រ, បញ្ហាវិសមភាព និង ការពង្រឹងសំណាញ់សុវត្ថិភាពសង្គម មិនត្រឹមតែជួយលើកកម្ពស់សន្តិភាព

និងសន្តិសុខ សម្រាប់ការអភិវឌ្ឍក្នុងពេលបច្ចុប្បន្នប៉ុណ្ណោះទេ; ប៉ុន្តែ វាក៏នឹងក្លាយជាមាគ៌ាទំនុកបំរុងមនុស្សជំនាន់-ក្រោយ ឱ្យអាចរស់នៅបាន ប្រកបដោយសុខសន្តិភាព និង សុខុមាលភាពខ្ពស់ផងដែរ ។

**ទី៤. ការពង្រឹងគុណភាពនៃការអប់រំ :** បច្ចុប្បន្ន, យុវជន បាន និង កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការ-ចូលរួមដឹកនាំប្រទេសទៅរកភាពរីកចម្រើន, នៅក្នុងឌីជីថលភាព និង វិសាលភាពថ្មី ។ ទន្ទឹមនេះ, ប្រទេសយើងមួយ-ចំនួនធំ ក៏កំពុងទទួលបាននូវផលលាភប្រជាសាស្ត្រ ។ លើមូលដ្ឋាននេះ, ការផ្តល់ និង ការពង្រឹងការអប់រំដល់ យុវជន ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាគន្លឹះសម្រាប់ភាពរឹងមាំនៃសេដ្ឋកិច្ច និង សម្រាប់ដោះស្រាយ បញ្ហាសង្គមនានា ។ ដូច្នេះ, ការដាក់ចេញនូវគោលនយោបាយអប់រំប្រកបដោយគុណភាព សម្រាប់យុវជន និង សម្រាប់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ គឺពិតជាការងារចាំបាច់បំផុត ។

**ទី៥. ការរៀបចំសង្គមឱ្យស្របនឹងការអភិវឌ្ឍន៍បច្ចេកវិទ្យា និង វិទ្យាសាស្ត្រ :** បដិវត្តន៍ឧស្សាហកម្មទី ៤ គឺជាការចាប់ផ្តើមដំណាក់កាលថ្មីនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ដោយសមត្ថភាពថ្មីៗនៃបច្ចេកវិទ្យា ព្រមទាំង របស់មនុស្ស និង ម៉ាស៊ីន ។ ទន្ទឹមនឹងការរីកចម្រើននេះ ពិភពលោកមានការប្រែប្រួលយ៉ាងឆាប់រហ័សលើគ្រប់ វិស័យ ដែលទាមទារឱ្យរដ្ឋាភិបាលធ្វើការពិនិត្យឡើងវិញ នូវក្របខ័ណ្ឌគតិយុត្តិ, ការរៀបចំយន្តការអនុវត្តច្បាប់, ក៏ ដូចជាបណ្តុះបណ្តាលមនុស្ស ឱ្យមានសមត្ថភាពស្របនឹងការរីកចម្រើននៃបច្ចេកវិទ្យាទាំងនេះ ។ ក្នុងន័យនេះ, រដ្ឋាភិបាលនៃប្រទេសនីមួយៗ ត្រូវរៀបចំជាគោលនយោបាយ ដើម្បីដោះស្រាយបញ្ហាប្រឈមផង និង ដើម្បីកសាង មូលដ្ឋានគ្រឹះសមស្រប សម្រាប់ទាញយកកាលានុវត្តភាពឱ្យបានជាអតិបរមាពីបដិវត្តឧស្សាហកម្មទី ៤ នេះផង ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !**

ខ្ញុំអាចនិយាយបានថា បទពិសោធន៍នៃការអភិវឌ្ឍនយោបាយរបស់កម្ពុជា នៅក្នុងយុគសម័យនៃប្រវត្តិ-សាស្ត្រទំនើបរបស់ពិភពលោក គឺនៅមានលក្ខណៈក្មេងខ្ចីនៅឡើយ ។ ប៉ុន្តែ, យើងកំពុងរៀនសូត្រយ៉ាងឆាប់រហ័ស ដើម្បីពង្រឹង «លទ្ធិប្រជាធិបតេយ្យប្រជាជន» របស់កម្ពុជា ឱ្យមានភាពរស់រវើក និង រឹងមាំ ។ តម្លៃស្នូលនៃ «លទ្ធិប្រជាធិបតេយ្យប្រជាជន» របស់យើង គឺ : ទី១- ការប្តូរប្តេជ្ញាលើកកម្ពស់ និង ការធានានូវការគោរពសិទ្ធិស្វ័យ សម្រេចរបស់ប្រជាជាតិកម្ពុជា នៅក្នុងអធិបតេយ្យភាព និងបូរណភាពទឹកដីដ៏ពេញលេញរបស់ខ្លួន ដោយគ្មានការ-ជ្រៀតជ្រែក និង រំលោភបំពានពីខាងក្រៅ; ទី២- ការធានារក្សាឱ្យបានដាច់ខាតនូវសន្តិភាព, ស្ថិរភាព និង ភាព-សុខដុមរមនាសង្គម ដែលជាបុព្វលក្ខខណ្ឌមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រទេស ក៏ដូចជាសម្រាប់ភាពក្សេម-ក្សាន្តរបស់ប្រជាជាតិ និង សម្រាប់ជីវភាពរស់នៅថ្លៃថ្នូរសមរម្យរបស់ប្រជាជន; ទី៣- ការគោរពប្រតិបត្តិយ៉ាង ខ្ជាប់ខ្ជួនឥតងាករេ នូវគោលការណ៍នីតិរដ្ឋ និង ប្រព័ន្ធនយោបាយសេរីពហុបក្ស ដែលក្នុងនេះ ប្រជាពលរដ្ឋមានសិទ្ធិ សេរីភាពគ្រប់យ៉ាង ដ៏ពេញលេញ នៅក្រោមវិធានថៃច្បាប់ ជាពិសេស សិទ្ធិក្នុងការជ្រើសអ្នកដឹកនាំប្រទេស តាម-រយៈការបោះឆ្នោត ជាទៀងទាត់ និង ដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌; និង ទី៤- ការប្តេជ្ញាអភិវឌ្ឍស្ថាប័នរដ្ឋ, ដោយឈរលើគោលការណ៍ប្រតិកុល្យភាព អភិបាលកិច្ចល្អ និង កុលាធិបតេយ្យ, ឱ្យក្លាយជាឧបករណ៍ប្រកប-ដោយប្រសិទ្ធភាព សក្តិសិទ្ធភាព និង ពោរពេញដោយសមត្ថភាព, សម្រាប់បម្រើប្រទេសជាតិ និង ប្រជាជនកម្ពុជា គ្រប់ស្រទាប់ជាន់ថ្នាក់ ។

ក្នុងរយៈពេលជាង ៣០ ឆ្នាំចុងក្រោយ នៃបទពិសោធន៍នយោបាយរបស់យើងខ្ញុំ ក្នុងអំឡុងពេលដែលគណបក្សរបស់ខ្ញុំ, គោលគឺ គណបក្សប្រជាជនកម្ពុជា, ស្ថិតនៅក្នុងតួនាទីនៃការដឹកនាំប្រទេស, កម្ពុជាសម្រេចបាននូវសមិទ្ធផលជាច្រើន, ពិតណាស់ ដោយមានការជួយជ្រោមជ្រែងពីមិត្តភក្តិរបស់យើង ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំជាន់ខ្ពស់នេះ ។ យើងបានធ្វើការយ៉ាងលំបាក ដើម្បីបញ្ចប់សង្គ្រាម ហើយសម្រេចបាននូវសន្តិភាព និងការបង្រួបបង្រួមជាតិដ៏ពេញលេញ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រទេស និងដែលបានធ្វើកម្ពុជានិរន្តងផុតពីឋានៈនៃប្រទេសចំណូលទាប ក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាប ហើយកំពុងតែសម្លឹងឆ្ពោះទៅមុខក្នុងមហិច្ឆតាប្រែក្លាយខ្លួនទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នាឆ្នាំ ២០៣០ ខាងមុខ ។ លើមូលដ្ឋាននេះ, កម្ពុជានឹងបន្តខិតខំប្រឹងប្រែងបន្តទៀត ក្នុងទិសដៅធ្វើឲ្យកាន់តែប្រសើរឡើងថែមទៀត នូវកិច្ចដំណើរការនយោបាយរបស់ខ្លួន និង នូវការអភិវឌ្ឍជាតិ តាមរយៈការខំប្រឹងប្រែងអស់សមត្ថភាព ដើម្បីពង្រឹង និង លើកកម្ពស់ «លទ្ធិប្រជាធិបតេយ្យប្រជាជន» ស្របតាមលក្ខណៈពិសេស និង សេចក្តីត្រូវការជាក់ស្តែងរបស់កម្ពុជា ដោយឈរលើមូលដ្ឋាននៃគុណតម្លៃស្នូល និង បណ្តាគោលការណ៍គ្រឹះទាំងឡាយ ដូចខ្ញុំបានរៀបរាប់ខាងលើ ។ ជាមួយគ្នានេះ, កម្ពុជាក៏បានត្រៀមខ្លួនរួចជាស្រេច ដើម្បីរួមចំណែកជាមួយដៃគូពាក់ព័ន្ធទាំងអស់ ក្នុងការធ្វើកិច្ចការចាំបាច់នានា សំដៅពង្រឹងសុខសន្តិភាព និង ជំនះឱ្យបាន នូវរាល់បញ្ហាប្រឈមចំពោះមុខ សម្រាប់ការអភិវឌ្ឍន៍ប្រទេស និង ប្រជាជាតិយើងទាំងអស់គ្នា ។

នៅចុងបញ្ចប់, ខ្ញុំសូមយកឱកាសនេះ សម្តែងនូវការអបអរសាទរ ជូនឯកឧត្តមប្រធានាធិបតី ស៊ី ជីនភីង (Xi Jinping) និង ជូនដល់បក្សកុម្មុយនីស្តចិនទាំងមូល ចំពោះកិច្ចដំណើរការមហាសន្និបាតតំណាងទូទាំងប្រទេសលើកទី ១៩ កន្លងទៅថ្មីៗនេះ ប្រកបដោយជោគជ័យជាប្រវត្តិសាស្ត្រ និង សូមជូនពរឱ្យកិច្ចប្រជុំរបស់យើងនាពេលនេះ ទទួលបាននូវលទ្ធផលដ៏ល្អត្រចះត្រចង់តាមការគ្រោងទុក ។

***សូមអរគុណ !***